ក្រុមមេធាវី ខេមឡ
CAMLAW GROUP

# ច្បាប់
# ស្តីពី
# សោធននិវត្តន៍ និងសោធន
# បាត់បង់សមត្ថភាពការងារ
# ចំពោះយោធិននៃកង
# យោធពលខេមរភូមិន្ទ
# ១៩៩៨

WWW.CAMLAW.COM.KH

រៀបចំភក្តីឡង់ PHEAKDEYLAW.COM.KH

# ច្បាប់

## ស្ដីពី

## របបសោធននិវត្តន៍និង

## សោធនបាត់បង់សមត្ថភាពការងារ

## ចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ

# ច្បាប់

## ស្តីពី

## របបសោធននិវត្តន៍និង
## សោធនបាត់បង់សមត្ថភាពការងារ
## ចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ

## ជំពូកទី ១
## របបសោធននិវត្តន៍

**មាត្រា ១ _**

យោធិនទាំង ២ ភេទ ដែលបានបំរើការងារក្នុងកងយោធពលខេមរភូមិន្ទ ហើយអាចចូលនិវត្តន៍បាន លុះតែបំពេញលក្ខខណ្ឌដូចខាងក្រោម ៖

ក _ បុរសត្រូវមានអាយុ ៥៥ ឆ្នាំ និងមានរយៈពេលបំរើការងារសរុប ២០ ឆ្នាំ យ៉ាងតិច ។

ខ _ នារីត្រូវមានអាយុ ៥០ ឆ្នាំ និងមានរយៈពេលបំរើការងារសរុប ១៥ ឆ្នាំ យ៉ាងតិច ។

រយៈពេលបំរើការងារ ២០ ឆ្នាំ និង ១៥ ឆ្នាំខាងលើនេះ ត្រូវមានរយៈពេលបំរើការងារក្នុងកង_យោធពលខេមរភូមិន្ទយ៉ាងតិច ៥ ឆ្នាំ ជាបន្តបន្ទាប់មុនពេលចូលនិវត្តន៍ ។

**មាត្រា ២ _**

យោធិនទាំង ២ ភេទ នៃកងយោធពលខេមរភូមិន្ទ អាចទទួលរបបសោធននិវត្តន៍បានត្រូវមានលក្ខខណ្ឌដូចខាងក្រោម ៖

ក _ របបសោធននិវត្តន៍អប្បបរមា

១ _ យោធិនដែលបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងមាត្រា ១ នៃច្បាប់នេះ ឬ

២ _ ចំពោះយោធិនដែលបានបំរើការងារនៅតំបន់លំបាក ការងារគ្រោះថ្នាក់ ឬការងារប៉ះពាល់សុខភាពចំនួន ១០ ឆ្នាំ ចំពោះបុរស និង ៨ ឆ្នាំ ចំពោះនារី លក្ខខណ្ឌអាយុនិងរយៈពេលបំរើការងារសរុបត្រូវបន្ថយ ៥ ឆ្នាំ ឬ

៣ _ ចំពោះយោធិនដែលបានបំរើការងារនៅតំបន់លំបាក ការងារគ្រោះថ្នាក់ ឬការងារប៉ះពាល់សុខភាពចំនួន ១២ ឆ្នាំ ចំពោះបុរស និង ៩ ឆ្នាំ ចំពោះនារី លក្ខខណ្ឌអាយុត្រូវបន្ថយ ៥ ឆ្នាំ តែពុំមានលក្ខខណ្ឌរយៈពេលបំរើការងារវែ្លរមទេ ឬ

៤ _ ចំពោះយោធិនដែលបានបំរើការងារនៅតំបន់លំបាក ការងារគ្រោះថ្នាក់ ឬការងារប៉ះពាល់សុខភាពចំនួន ១៥ ឆ្នាំ ចំពោះបុរស និង ១០ ឆ្នាំ ចំពោះនារី ពុំមានលក្ខខណ្ឌអាយុនិងរយៈពេលបំរើការងាររួមដូចមានចែងក្នុងមាត្រា ១ ទេ ឬ

៥ _ ចំពោះយោធិនដែលបានបំរើការងារផ្សេងៗ ក្នុងកងយោធពលខេមរភូមិន្ទ ចំនួន ២០ ឆ្នាំ ចំពោះបុរស និង ១៥ ឆ្នាំ ចំពោះនារី ពុំមានលក្ខខណ្ឌអាយុនិងរយៈពេលបំរើការងាររួមដូចមានចែងក្នុងមាត្រា ១ ទេ ។

ខ _ របបសោធននិវត្តន៍អតិបរមា ៖

១ _ បុរសត្រូវមានអាយុ ៥៥ ឆ្នាំ និងរយៈពេលបំរើការងារក្នុងកងយោធពលខេមរ_ភូមិន្ទចំនួន ២០ ឆ្នាំ នារីត្រូវមានអាយុ ៥០ ឆ្នាំ និងរយៈពេលបំរើការងារក្នុងកងយោធពលខេមរភូមិន្ទចំនួន ១៥ ឆ្នាំ ឬ

២ _ បុរសត្រូវមានអាយុ ៥០ ឆ្នាំ និងរយៈពេលបំរើការងារនៅតំបន់លំបាក ការងារគ្រោះថ្នាក់ ឬការងារប៉ះពាល់សុខភាពចំនួន ១៥ ឆ្នាំ ក្នុងកងយោធពលខេមរភូមិន្ទ ។ នារីត្រូវមានអាយុ ៤៥ ឆ្នាំ និងរយៈពេលបំរើការងារនៅតំបន់លំបាក ការងារគ្រោះថ្នាក់ ឬការងារប៉ះពាល់សុខភាព ចំនួន ១០ ឆ្នាំ ក្នុងកងយោធពលខេមរភូមិន្ទ ឬ

៣ _ ឧត្តមសេនីយ៍ ឬវីរជន ក្នុងកងយោធពលខេមរភូមិន្ទដែលបានបំពេញលក្ខខណ្ឌដូចមានចែងនៅចំណុច "ក" ក្នុងមាត្រា ២ ត្រូវបានទទួលរបបសោធននិវត្តន៍អតិបរមា ឬ

៤ _ ចំពោះយោធិនពិការដែលនៅបំរើការងារជាប់រហូតដល់ចូលនិវត្តន៍ ត្រូវបានទទួលរបបសោធននិវត្តន៍អតិបរមាដូចមានចែងក្នុងចំណុច "ខ" នៃមាត្រា ២ ។

មាត្រា ៣ _

របៀបគិតរយៈពេលបំរើការងារព្រមទាំងការកំណត់តំបន់លំបាក ការងារគ្រោះថ្នាក់ ឬការងារប៉ះពាល់សុខភាពដែលមានចែងក្នុងមាត្រា ១ និងមាត្រា ២ ត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ៤ _

យោធិនទាំងពីរភេទ ដែលមិនបានបំពេញលក្ខខណ្ឌដូចមានចែងក្នុងចំណុច "ក" មាត្រា ២ នៃច្បាប់នេះ មិនទទួលប្រាក់សោធននិវត្តន៍នេះឡើយ តែទទួលប្រាក់ឧបត្ថម្ភផ្ដាច់សរុបមួយ ស្មើនឹងបៀវត្សប្រចាំខែចុងក្រោយរបស់សាមីខ្លួន គុណនឹងចំនួនឆ្នាំដែលបានបំពេញការងារ ។ ប្រាក់ឧបត្ថម្ភនេះមិនត្រូវតិចជាងបៀវត្ស ៦ ខែចុងក្រោយរបស់សាមីខ្លួនឡើយ ។

មាត្រា ៥ _

ប្រាក់សោធននិវត្តន៍ត្រូវកំណត់ដូចខាងក្រោម ៖

១_ ប្រាក់សោធននិវត្តន៍អប្បបរមាប្រចាំខែស្មើ ៥០ ភាគរយនៃបៀវត្សឋានន្តរសក្តិប្រចាំខែចុងក្រោយ ។ ប្រាក់នេះត្រូវបានអត្រាបន្ថែម ១ឆ្នាំ ២ ភាគរយទៀត រាប់ចាប់ពីឆ្នាំទី ៤ នៃរយៈពេលបំពេញការងារយោធា ឬ ចាប់ពីឆ្នាំទី ៦ នៃរយៈពេលបំពេញការងាររដ្ឋ ។ តែសរុបមិនត្រូវលើស ៨០ ភាគរយនៃប្រាក់សោធននិវត្តន៍អតិបរមាឡើយ ។

២_ ប្រាក់សោធននិវត្តន៍អតិបរមាប្រចាំខែស្មើ ៨០ ភាគរយនៃបៀវត្សឋានន្តរសក្តិប្រចាំខែចុងក្រោយ ។

៣_ ប្រាក់សោធននិវត្តន៍ទាបបំផុតមិនត្រូវតិចជាងបៀវត្សឋានន្តរសក្តិអប្បបរមារបស់នាយទាហានឡើយ ។

៤_ យោធិនដែលបានចូលបំពេញការងារក្នុងយោធាមុនឆ្នាំ ១៩៧០ ឬរំដោះត្រូវបានអត្រាបន្ថែម ២០ ភាគរយនៃបៀវត្សឋានន្តរសក្តិថែមទៀត ។

៥_ យោធិនដែលចូលបំពេញការងារក្នុងយោធាមុនឆ្នាំ ១៩៧៩ ត្រូវបានអត្រាបន្ថែម ១៥ ភាគរយនៃបៀវត្សឋានន្តរសក្តិថែមទៀត ។

៦_ យោធិនដែលធ្វើការនៅតំបន់លំបាក ការងារគ្រោះថ្នាក់ ឬការងារប៉ះពាល់សុខភាព ត្រូវបានអត្រាបន្ថែម ១៥ ភាគរយនៃបៀវត្សឋានន្តរសក្តិថែមទៀត ។

មាត្រា ៦ _

របបបន្ថែមផ្សេងៗសម្រាប់ចូលនិវត្តន៍ ៖

១_ ត្រូវទទួលប្រាក់បន្ថែមមួយលើកស្មើ ៨ ខែ នៃបៀវត្សប្រចាំខែចុងក្រោយរបស់សាមីខ្លួន ។

២_ អាចសុំច្បាប់ឈប់សម្រាកពី ៦ ដល់ ១២ ខែ គិតតាមឋានន្តរសក្តិ និងករណីចាំបាច់របស់យោធិនម្នាក់ៗមុនពេលចូលនិវត្តន៍ ។

៣_ ក្រោយពីចូលនិវត្តន៍ហើយ បើមានជំងឺ ឬគ្រោះថ្នាក់ ឬស្លាប់ត្រូវបានទទួលរបបធានារ៉ាប់រងសង្គមដូចមន្ត្រី រាជការស៊ីវិលចូលនិវត្តន៍ដទៃទៀត ។

មាត្រា ៧_

យោធិនទាំង ២ ភេទចូលនិវត្តន៍ ឬបាត់បង់សមត្ថភាពការងារមានសិទ្ធិស្លៀកពាក់ឯកសណ្ឋានរបស់កងយោធពលខេមរភូមិន្ទក្នុងពិធីបុណ្យជាតិផ្សេងៗ ។ ប្រាក់ចំណាយឯកសណ្ឋាននេះជាបន្ទុករបស់ថវិការដ្ឋ ។

មាត្រា ៨_

យោធិនទាំងពីរភេទដែលបានបំពេញលក្ខខណ្ឌចូលនិវត្តន៍ អាចបន្តការងារ ១ឆ្នាំម្តងៗដោយមានការស្នើសុំពីសាមីខ្លួន និងមានការយល់ព្រមពីស្ថាប័នមានសមត្ថកិច្ចផង ។

រយៈពេលសុំបន្តការងារមិនអាចលើសពី ៥ ឆ្នាំឡើយ ។

## ជំពូកទី ២
## របបសោធនបាត់បង់សមត្ថភាពការងារ

មាត្រា ៩_

យោធិនទាំងពីរភេទដែលបាត់បង់សមត្ថភាពការងារ ៖

ក_ ដោយសារជំងឺរ៉ាំរ៉ៃ ចាស់ជរា គ្រោះថ្នាក់ផ្សេងៗតែមិនបាត់បង់សរីរាង្គណាមួយ ហើយមិនគ្រប់លក្ខណៈជាយោធិនពិការអាចទទួលរបបសោធនបាត់បង់សមត្ថភាពការងារបាន លុះត្រាតែបានបំរើការងាររួមយ៉ាងតិច ១៥ ឆ្នាំ ចំពោះបុរស និង ១០ ឆ្នាំ ចំពោះនារី ។

រយៈពេល ១៥ ឆ្នាំ និង ១០ ឆ្នាំ ខាងលើនេះ ត្រូវមានរយៈពេលបំរើការងារក្នុងកងយោធពលខេមរភូមិន្ទយ៉ាងតិច ៥ ឆ្នាំ ជាបន្តបន្ទាប់មុនពេលចូលបាត់បង់សមត្ថភាពការងារ ។

ខ_ ដោយសារបំពេញភារកិច្ចឬធ្វើការនៅតំបន់លំបាក ការងារគ្រោះថ្នាក់ ឬការងារប៉ះពាល់សុខភាព ដោយពុំគិតពីអាយុ និងរយៈពេលបំរើការងាររួមឡើយ ហើយត្រូវបានកំរិតការបាត់បង់សមត្ថភាពការងារជា ៣ ថ្នាក់ដូចខាងក្រោម ៖

- ថ្នាក់ទី ១ បាត់បង់សមត្ថភាពការងារលើសពី ៨០ ភាគរយ
- ថ្នាក់ទី ២ បាត់បង់សមត្ថភាពការងារលើសពី ៦០ ភាគរយ
- ថ្នាក់ទី ៣ បាត់បង់សមត្ថភាពការងារលើសពី ៤០ ភាគរយ ។

មាត្រា ១០._

លក្ខខណ្ឌជាក់ស្តែងនៃការបាត់បង់សមត្ថភាពការងារសម្រាប់ថ្នាក់នីមួយៗ ត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ១១._

យោធិនទាំងពីរភេទ នៃកងយោធពលខេមរភូមិន្ទ ដែលមិនបានបំពេញលក្ខខណ្ឌដូចមានចែងក្នុង មាត្រា ៩ នៃច្បាប់នេះ រដ្ឋមិនផ្តល់របបសោធនបាត់បង់សមត្ថភាពការងារឡើយ ។ ករណីនេះ រដ្ឋឧបត្ថម្ភមួយលើកគត់ ស្មើបៀវត្សរបស់ខ្លួន គុណចំនួនឆ្នាំដែលបានបំពេញការងារ ប៉ុន្តែទឹកប្រាក់នេះ មិនត្រូវតិចជាងបៀវត្ស ៦ ខែរបស់សាមីខ្លួន ឡើយ ។

មាត្រា ១២._

ប្រាក់សោធនបាត់បង់សមត្ថភាពការងារប្រចាំខែ ចែកចេញជាពីរផ្នែកដូចខាងក្រោម ៖

ក_ ប្រាក់សោធនបាត់បង់សមត្ថភាពការងារប្រចាំខែស្មើនឹង ៥០ ភាគរយ នៃបៀវត្សឋានន្តរសក្តិចុងក្រោយត្រូវបានផ្តល់ចំពោះ ៖

១_ យោធិនដែលបានបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងចំណុច " ក " ក្នុង មាត្រា ៩ នៃច្បាប់នេះ ។

២_ យោធិនដែលបានបំពេញការងារនៅតំបន់លំបាក ការងារគ្រោះថ្នាក់ ឬប៉ះពាល់សុខភាពចំនួន ១០ ឆ្នាំ ចំពោះបុរស និង ៨ ឆ្នាំ ចំពោះនារី ។

ប្រាក់សោធនបាត់បង់សមត្ថភាពការងារអប្បបរមាប្រចាំខែស្មើ ៥០ ភាគរយ នៃបៀវត្សឋានន្តរសក្តិប្រចាំខែចុងក្រោយ ត្រូវបានអត្រាបន្ថែម ១ ឆ្នាំ ១.៥ ភាគរយទៀតរាប់ចាប់ពីឆ្នាំទី ៤ នៃរយៈពេលបំពេញការងារយោធា ឬចាប់ពីឆ្នាំទី ៦ នៃរយៈពេលបំពេញការងាររដ្ឋ ។ តែប្រាក់សរុបមិនត្រូវលើស ៦០ ភាគរយ នៃប្រាក់សោធនបាត់បង់សមត្ថភាពការងារឡើយ ។

ខ_ ប្រាក់សោធនបាត់បង់សមត្ថភាពការងារ ៖

_ យោធិនបាត់បង់សមត្ថភាពការងារថ្នាក់ទី ១ ទទួលបាន ១០០ ភាគរយ នៃបៀវត្សឋានន្តរសក្តិប្រចាំខែចុងក្រោយរបស់សាមីខ្លួន ។

_ យោធិនបាត់បង់សមត្ថភាពការងារថ្នាក់ទី ២ ទទួលបាន ៨០ ភាគរយ នៃបៀវត្សឋានន្តរសក្តិប្រចាំខែចុងក្រោយរបស់សាមីខ្លួន ។

_ យោធិនបាត់បង់សមត្ថភាពការងារថ្នាក់ទី ៣ ទទួលបាន ៦០ ភាគរយ នៃបៀវត្សឋានន្តរសក្តិប្រចាំខែចុងក្រោយរបស់សាមីខ្លួន ។

ប្រាក់សោធនបាត់បង់សមត្ថភាពការងារទាបបំផុតមិនត្រូវតិចជាង ៩០ ភាគរយនៃបៀវត្សឋានន្តរសក្តិអប្បបរមារបស់នាយទាហានឡើយ ។

យោធិនដែលធ្វើការនៅតំបន់លំបាក ការងារគ្រោះថ្នាក់ ឬប៉ះពាល់សុខភាពត្រូវបានអត្រាបន្ថែម ១៥ ភាគរយនៃបៀវត្សឋានន្តរសក្តិថែមទៀត ។

យោធិនបាត់បង់សមត្ថភាពការងារថ្នាក់ទី ១ ត្រូវបានទទួលប្រាក់ឧបត្ថម្ភប្រចាំខែបន្ថែមសម្រាប់អ្នកបំពេញកិច្ចការក្នុងផ្ទះស្មើនឹងប្រាក់បៀវត្សអប្បបរមា និងប្រាក់បំណាច់របស់យុទ្ធជនម្នាក់ ។

ចំពោះវីរជននៃកងយោធពលខេមរភូមិន្ទត្រូវបានទទួលអត្រាបន្ថែម ១០ ភាគរយ នៃបៀវត្សឋានន្តរសក្តិថែមទៀត ។

មាត្រា ១៣ _

របបបន្ថែមផ្សេងៗចំពោះយោធិនបាត់បង់សមត្ថភាពការងារ ៖

១_ ត្រូវបានទទួលប្រាក់បន្ថែម ១ លើកស្មើនឹង ៦ ខែ នៃបៀវត្សប្រចាំខែចុងក្រោយរបស់សាមីខ្លួន ។

២_ បើគ្មានទីបង្អែក រដ្ឋទទួលបន្ទុកយកទៅស្នាក់នៅមជ្ឈមណ្ឌលរបស់រដ្ឋ ។ ក្នុងករណីនេះសាមីខ្លួនទទួលប្រាក់បន្ថែមខាងលើតែ ៥០ ភាគរយប៉ុណ្ណោះ ។

៣_ ពេលមានជំងឺ គ្រោះថ្នាក់ ឬស្លាប់ត្រូវបានទទួលរបបធានារ៉ាប់រងសង្គមដូចយោធិនចូលនិវត្តន៍ដែរ ។

មាត្រា ១៤ _

ប្រាក់ធានារ៉ាប់រងសម្រាប់គ្រួសារ ក្រោយមរណភាពរបស់និវត្តជន និងអ្នកបាត់បង់សមត្ថភាពការងាររដ្ឋធានាដោះស្រាយតែម្តងគត់ស្មើនឹងប្រាក់បៀវត្ស និងប្រាក់បំណាច់របស់សាមីជន គុណនឹង ១២ ខែ ។

## ជំពូកទី ៣
## អំពីអន្តរប្បញ្ញត្តិ

មាត្រា ១៥ _

ប្រាក់សោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងាររបស់យោធិន នៃកងយោធពលខេមរភូមិន្ទបានមកពីប្រាក់ឧបត្ថម្ភរបស់រដ្ឋរៀងរាល់ខែស្មើនឹង ៦ ភាគរយ នៃបៀវត្សឋានន្តរសក្តិរបស់យោធិនម្នាក់ៗ ។

## ជំពូកទី ៤

## អវសានប្បញ្ញត្តិ

**មាត្រា ១៦**

បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍ ។

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
អនុម័តនៅថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៩៤
នាសម័យប្រជុំសាមញ្ញលើកទី ៣ នីតិកាលទី ១ ។
ភ្នំពេញ ថ្ងៃទី២៨ ខែ តុលា ឆ្នាំ ១៩៩៤
ប្រធានរដ្ឋសភាស្តីទី

ឡុយ ស៊ីមឈាង